# សូមប្រយ័ត្ន ចំពោះសារបែបនេះ

បើអ្នកចុចលើតំណភ្ជាប់ នោះអ្នកនឹងចូលទៅកាន់គេហទំព័រក្លែងក្លាយ ដែលដូចនឹងគេហទំព័រ ឬកម្មវិធីតេឡេក្រាមទាំងស្រុង ហើយបើអ្នកធ្វើតាមការណែនាំ អ្នកនឹងបាត់គណនីតេឡេក្រាមភ្លាម ក្នុងករណីដែលតេឡេក្រាមអ្នកមិនបាន ដាក់មុខងារផ្ទៀងផ្ទាត់២ជាន់ ឬ 2FA។




## ១. ឈ្មោះគណនីក្លែងក្លាយ

**telegrem.** ជាឈ្មោះបន្លំ ត្រង់អក្សរ **e** និងសញ្ញា **.** ឈ្មោះគណនីផ្លូវការរបស់ តេឡេក្រាមគឺ **Telegram** និងមាននិមិត្តសញ្ញាធីក បញ្ជាក់គណនីផ្លូវការនៅខាងចុង

## ២. គណនីទើបបង្កើតថ្មី

គណនីនេះទើបបង្កើត នៅខែវិច្ឆិកា ឆ្នាំ២០២៥ នេះទេ ហើយប្រើលេខទូរស័ព្ទ របស់ប្រទេស ឥណ្ឌូណេស៊ី

## ៣. តំណភ្ជាប់ក្លែងក្លាយ

**https://fj8l.boy6.eu.cc** មិនមែនតំណភ្ជាប់ផ្លូវការរបស់តេឡេក្រាម ទេ។ តំណភ្ជាប់ផ្លូវការរបស់តេឡេក្រាម មានដូចជា៖ **telegram.org** ឬ **web.telegram.org** ឬ **t.me**

## ៤. បំភ័យ និងឱ្យធ្វើសកម្មភាពបន្ទាន់

សារនេះបញ្ជាក់ថា គណនីតេឡេក្រាមអ្នក និងត្រូវបង្កក ឬផ្អាកដំណើរការ ប្រសិនបើអ្នកមិនធ្វើការផ្ទៀងផ្ទាត់ ក្នុងរយៈពេលកំណត់ ២៤ម៉ោង

DigitalHub101
digitalhub101.com